**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## លក្ខខណ្ឌ និង នីតិវិធី ក្នុងការគ្រប់គ្រង កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- បានឃើញ អនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៣៨អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៩ ស្តីពីគ្រប់គ្រង និងការត្រួតពិនិត្យ ការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និង ការប្រើប្រាស់អាវុធជាតិផ្ទុះ គ្រប់ប្រភេទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីល័ក្ខខ័ណ្ឌ និង នីតិវិធីក្នុងការគ្រប់គ្រងកាំភ្លើង គ្រាប់បាញ់

និងគ្រឿងផ្ទុះ ដែលត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលប្រកាសដោយព្រះរាជក្រម លេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០០៥ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណងការពារសន្តិសុខ សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ។

**មាត្រា ៣.-**

វិសាលភាពនៃអនុក្រឹត្យនេះគ្របដណ្តប់លើ ការកាន់កាប់ ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការចែកចាយ ការឱ្យខ្ចី ការជួល ការផលិត ការកែច្នៃដំឡើង ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការស្តុកកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់ ។

**មាត្រា ៤.-**

វាក្យសព្ទ ដូចចែងក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម ÷

ក. កាំភ្លើងកំណត់សញ្ញា : សំដៅដល់ កាំភ្លើងខ្លី ឬ វែងដែលគេផលិតឡើងក្នុងគោលបំណងដើម្បីបាញ់ចេញបន្លឺសំឡេង ឬ ចេញភ្លើង ផ្សេង សម្រាប់កំណត់សញ្ញា ឬ ទីកន្លែង ។

ខ. កាំភ្លើងកីឡា : សំដៅដល់ កាំភ្លើងខ្លី ឬ វែងដែលគេផលិតឡើងក្នុងគោលបំណង ដើម្បីហាត់ហ្វឹកហ្វឺន ឬ ប្រកួតក្នុងសកម្មភាពកីឡា ។

គ. កាំភ្លើងសិល្បៈ : សំដៅដល់កាំភ្លើងដែលផលិតឡើងក្នុងគោលបំណងប្រើប្រាស់សម្រាប់ការសំដែងសិល្បៈ អាចបាញ់ចេញបន្លឺសម្លេង ឬ អណ្តាតភ្លើងតែគ្មានក្បាលគ្រាប់ ។

ឃ. បំពង់ និងគ្រាប់កាំជ្រួចផ្ទុះលម្អ : សំដៅដល់ ឧបករណ៍ដែលគេផលិតឡើង ក្នុងគោលបំណងដើម្បីបាញ់បញ្ជូនគ្រាប់កាំជ្រួចទៅលើអាកាស ផ្ទុះបន្លឺសម្លេង និង/ឬ បែកចេញផ្កាភ្លើង គ្មានបំណែកអម្បែងលោហៈ ។

ង. គ្រាប់បាញ់ : សំដៅដល់ គ្រាប់ ឬកិបសម្រាប់បាញ់ជាមួយកាំភ្លើងដូចបានចែងក្នុងកថាខណ្ឌ ក.ខ.គ និង ឃ ។

ច. គ្រឿងផ្ទុះ : សំដៅដល់ កិបផ្ទុះ ខ្សែឆ្នួនផ្ទុះ ខ្សែឆ្នួនឆេះ រំសេវ ជាតិផ្ទុះ និង សារធាតុផ្ទុះគ្រប់ប្រភេទ ទោះជាមានដើមកំណើតពីអ្វីក៏ដោយសម្រាប់បម្រើសេវាកម្មសាធារណៈ និងវិស្វកម្មស៊ីវិល ឬ ផ្ទុះលម្អ ។

## ជំពូកទី ២
## លក្ខខណ្ឌ និង នីតិវិធី
## ក្នុងការគ្រប់គ្រង និងការអនុញ្ញាតឱ្យប្រើប្រាស់

**មាត្រា ៥.-**

កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវចុះបញ្ជីគ្រប់គ្រងតាមគំរូឯកភាពកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦.-**

លក្ខខណ្ឌក្នុងការអនុញ្ញាតឱ្យប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដូចខាងក្រោម ÷

- អ្នកស្នើសុំត្រូវតែជារូបវន្តបុគ្គល ដែលមានសញ្ជាតិខ្មែរ មានអាយុ ១៨ ឆ្នាំឡើង និងមានទីតិសម្បទាគ្រប់គ្រាន់ ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ដែលបានបំពេញបែបបទ និងចុះបញ្ជីត្រឹមត្រូវតាមច្បាប់ ។
- គោលបំណង និងសំណូមពរ នៃការស្នើសុំ ត្រូវស្របនឹងភាពចាំបាច់ក្នុងមុខរបរ អាជីព ឬ វិជ្ជាជីវៈ ។
- កាំភ្លើង គ្រាប់បាញ់ ឬ គ្រឿងផ្ទុះ ត្រូវបានផលិតឡើងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស មានប្រវត្តិ និងអត្តសញ្ញាណច្បាស់លាស់ ។
- មានការធានាទទួលខុសត្រូវលើផលវិបាកផ្សេងៗ ដែលកើតមានឡើង ។
- គោរពការណែនាំរបស់ក្រសួងមានសមត្ថកិច្ច ពីវិធាននានា ក្នុងការគ្រប់គ្រង ឬកិច្ចការពារសុវត្ថិភាព និរភ័យក្នុងការដឹកជញ្ជូន ការស្តុក និងការបញ្ចេញប្រើប្រាស់ ។
- បំពេញកាតព្វកិច្ចផ្សេងទៀតដែលច្បាប់បានកំណត់ ។

**មាត្រា ៧.-**

នីតិវិធីក្នុងការស្នើសុំលិខិតអនុញ្ញាត ឬ ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៨.-**

បរិមាណ ប្រភេទ គុណភាពកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ ស្របតាមល័ក្ខខ័ណ្ឌ ដូចបានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះ ត្រូវពិនិត្យសម្រេចដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៩.-**

កាំភ្លើង គ្រាប់បាញ់ ឬគ្រឿងផ្ទុះ និងលិខិតអនុញ្ញាតទាំងឡាយ ឬប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់ត្រូវតែបានបង្ហាញដល់ភ្នាក់ងារមានសមត្ថកិច្ចនៅពេលមានសំណូមពរត្រួតពិនិត្យ ។

## ជំពូកទី ៣
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ១០.-**

ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការចែកចាយ ការជួល ការផលិត ការកែច្នៃដំឡើង ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការស្តុកកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១១.-**

ការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងគ្រឿងផ្ទុះ សម្រាប់បម្រើសេវាកម្មសាធារណៈ និងវិស្វកម្មស៊ីវិល ដូចបានចែងក្នុងកថាខណ្ឌ ច មាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវដោយក្រសួងមហាផ្ទៃ ។

**មាត្រា ១២.-**

ការដឹកជញ្ជូនគ្រឿងផ្ទុះសម្រាប់បម្រើសេវាកម្មសាធារណៈ និងវិស្វកម្មស៊ីវិលត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មធ្យោបាយដឹកជញ្ជូន និង ការពារសុវត្ថិភាព និរភ័យ ត្រូវរ៉ាប់រងដោយកងកម្លាំងនគរបាលជាតិ ។

**មាត្រា ១៣.-**

ឃ្លាំងស្តុកគ្រឿងផ្ទុះត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌបច្ចេកទេសអំពីប្រព័ន្ធការពារសុវត្ថិភាព និរភ័យដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤.-**

ស្ថាប័នសាធារណៈ អង្គការប្រតិបត្តិករ ក្រុមហ៊ុន ការដ្ឋាន កសិដ្ឋាន សិប្បកម្មដ្ឋាន និងអតិថិជនដែលមានតម្រូវការប្រើប្រាស់គ្រឿងផ្ទុះត្រូវសុំអាជ្ញាប័ណ្ណពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤
## ទោសប្បញ្ញត្តិ

**មាត្រា ១៥.-**

ជនណា ដែលប្រព្រឹត្តផ្ទុយពីខ្លឹមសារ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១៦.-**

ក្នុងរយៈពេល ៣ (បី) ខែ យ៉ាងយូរ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ជនណាដែលបាន កាន់កាប់ កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវយកមកចុះបញ្ជីនៅក្រសួងមហាផ្ទៃជាកំហិត ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៨



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ